**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១១៩៤ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០១/២៦៤ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១ ស្តីពីនីតិសារជាតិ នៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៧៨ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៨ ស្តីពីវិសោធនកម្ម មាត្រា ៨, ៩ និង ១១ នៃជំពូក៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០១/២៦៤ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១ ស្តីពីនីតិសារជាតិ នៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាភិបាលផ្ទេរសិទ្ធិនៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា

**សម្រេច**

**មាត្រា ១** : តែងតាំងជំនួយការប្រធានក្រុមប្រឹក្សាភិបាលផ្ទេរសិទ្ធិ នៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ចំនួន ០២រូប ៖

១-លោកស្រី **ខឹម សុគន្ធា** មានឋានៈស្មើ អគ្គនាយករង
២-លោកស្រី **កេត ផាន់ណារី** មានឋានៈស្មើ ប្រធាននាយកដ្ឋាន។

**មាត្រា ២** : តែងតាំងជំនួយការអនុប្រធានអចិន្ត្រៃយ៍ក្រុមប្រឹក្សាភិបាល នៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ចំនួន ០២ រូប ៖

១-លោក **ជា ច័ន្ទបូរ** មានឋានៈស្មើ ប្រធាននាយកដ្ឋាន
២-លោក **ជា មិនា** មានឋានៈស្មើ ប្រធាននាយកដ្ឋាន។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាភិបាលផ្ទេរសិទ្ធិនៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ និងមាត្រា២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១២ កើត ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០១៨
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ